Embassy of Japan

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់។

ទូលបង្គំជាខ្ញុំនិងខ្ញុំ **គូម៉ាម៉ារុ យូជិ** ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា សូមគោរពថ្វាយព្រះពរនិងជូនពរឆ្នាំថ្មីជូនសម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជានាឱកាសឆ្នាំថ្មីឆ្នាំ២០១៤នេះ។ ខ្ញុំសូមក្រាបបង្គំថ្វាយនិងជំរាបផ្ញើរជូននូវសារលិខិតស្វាគមន៍នាឱកាសឆ្នាំថ្មីនេះផងដែរ។

ឆ្នាំ២០១៣ គឺជាឆ្នាំដែលសាកសមក្នុងការរំលឹកខួបអនុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងការទូតរវាងប្រទេសជប៉ុននិងកម្ពុជា។ បើយើងរំលឹកមើលទៅលើរយៈពេលពេញមួយឆ្នាំមុននេះ ខ្ញុំគិតថាគឺជាឆ្នាំដែលសាកសមទៅនឹងតំលៃនៃខួបអនុស្សាវរីយ៍ ដោយសារតែមានការប្រារព្ធនូវព្រឹត្តិការណ៍បំលាស់ប្តូរជាច្រើនសណ្ឋាន។ ជាលទ្ធផលក្នុងរយៈពេលតែមួយឆ្នាំ យើងបានប្រារព្ធកម្មវិធីសរុបមានចំនួនជាង១២០កម្មវិធី។ ក្នុងនោះកាលពីខែកុម្ភៈកន្លងទៅនេះ មានអ្នកចូលរួមប្រមាណជាង៧០០០នាក់ក្នុងមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាដែលបានប្រារព្ធឡើងនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ ជាងនេះទៅទៀត មានការបង្ហាញជូននូវព្រឹត្តិការណ៍ផ្សេងៗនៃវប្បធម៌ប្រពៃណីនិងទំនើបរបស់ជប៉ុន កម្មវិធីប្រគុំតន្ត្រី និងកម្មវិធីបំលាស់ប្តូរសិល្បៈជាច្រើនក្នុងរយៈពេលមួយឆ្នាំនោះផងដែរ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងអស់ពីដួងចិត្តចំពោះប្រជាជនកម្ពុជាក៏ដូចជាស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានអញ្ជើញចូលរួមនិងអបអរសាទរខួបអនុស្សាវរីយ៍មួយនេះឱ្យមានលក្ខណៈអធិកអធមនិងប្រកបដោយផ្លែផ្កា។

នាខែកុម្ភៈចាប់ពីថ្ងៃទី២០ ដល់ ថ្ងៃទី២៤ ឆ្នាំនេះ យើងនឹងមានរៀបចំមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាលើកទី៣។ នៅក្នុងលិខិតមួយនេះ ខ្ញុំបានភ្ជាប់ជូននូវប័ណ្ណប្រកាសរបស់កម្មវិធីផងដែរ។ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែងប្រសិនបើសម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អញ្ជើញចូលរួមជាកិត្តិយសនៅក្នុងឱកាសដ៏រីករាយនិងមានអត្ថន័យនេះ។

ជាងនេះទៅទៀត អ្វីដែលជាការកត់សំគាល់ដ៏ពិសេសនៃខួបអនុស្សាវរីយ៍លើកទី៦០នោះ គឺជាបំលាស់ប្តូរនៃដំណើរទស្សនកិច្ចផ្លូវការរវាងនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ។ កាលពីខែវិច្ឆិកាកន្លងទៅនេះ ឯកឧត្តម **ស៊ីនហ្សូ អាបេ** នាយករដ្ឋមន្ត្រីជប៉ុន បានធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ដែលជាដំណើរ

ទស្សកិច្ចផ្លូវការជាថ្មីម្តងទៀត ក្នុងរយៈពេល១៣ឆ្នាំ នៃដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីជប៉ុនមកកាន់ប្រទេសកម្ពុជា។

បន្ទាប់ពីនោះផងដែរ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនផងដែរកាលពីខែធ្នូកន្លងទៅនេះ។ នៅក្នុងកិច្ចប្រជុំកំពូលទ្វេភាគីដែលត្រូវបានប្រារព្ធធ្វើឡើងនាពេលនោះ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានសំរេចពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរតាមរយៈការតម្លើងឋានៈទំនាក់ទំនងប្រទេសទាំងពីរពី **"ភាពជាដៃគូរថ្មីថ្មោង"** ទៅជា **"ភាពជាដៃគូរយុទ្ធសាស្ត្រ"** ដែលប្រទេសទាំងពីរនឹងចូលរួមសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិជាងមុន ក្នុងដំណោះស្រាយបញ្ហាប្រឈមទាំងក្នុងតំបន់និងអន្តរជាតិ។

ប្រទេសជប៉ុននឹងបន្តគាំទ្រនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកំណែទំរង់នានានិងការពីតបន្តឹងលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋជាដើម។

បើយើងក្រលេកមើលទៅលើវិស័យសេដ្ឋកិច្ចវិញក៏មានសកម្មភាពគួរឱ្យកត់សម្គាល់ផងដែរ។ នៅក្នុងខែកុម្ភៈឆ្នាំមុន គណៈប្រតិភូដ៏ធំមួយនៃសហព័ន្ធពាណិជ្ជកម្មជប៉ុនដែលហៅកាត់ថា **KEIDANREN** បានមកធ្វើទស្សកិច្ចនៅកម្ពុជា។ ចំនួនក្រុមហ៊ុនជប៉ុននៅប្រទេសកម្ពុជាក៏មានការកើនឡើងជាបន្តបន្ទាប់ ហើយបច្ចុប្បន្ននេះមានក្រុមហ៊ុនចំនួន១១៨ បានចុះបញ្ជីជាសមាជិកអចិន្ត្រៃយ៍នៃសមាគមពាណិជ្ជកម្មជប៉ុននៅកម្ពុជាដែលហៅកាត់ថា **JBAC** ។ ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនៃបរិយាកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា ប្រទេសទាំងពីរនឹងបន្តសហប្រតិបត្តិការគ្នាក្នុងការអភិវឌ្ឍបរិយាកាសវិនិយោគ តាមរយៈកិច្ចប្រជុំស្តីអំពីវិស័យឯកជននិងសាធារណៈជប៉ុន-កម្ពុជា។

ចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចវិញ ប្រទេសជប៉ុនបាននិងកំពុងជួយប្រទេសកម្ពុជាក្នុងឋានៈជាប្រទេសផ្តល់ជំនួយធំជាងគេបំផុតចាប់តាំងពីឆ្នាំ១៩៩២។ ជំនួយអភិវឌ្ឍផ្លូវការរបស់ប្រទេសជប៉ុន មិនត្រឹមតែមានទំហំថវិការយ៉ាងច្រើននោះទេ តែវាក៏មានលក្ខណៈទូលំទូលាយផងដែរ។ ជំនួយអភិវឌ្ឍផ្លូវការរបស់ប្រទេសជប៉ុនបានជួយឧបត្ថម្ភប្រទេសកម្ពុជាយ៉ាងច្រើនតាមរយៈគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាស្ពានអ្នកលឿង ការជួសជុលផ្លូវជាតិលេខ១និងលេខ៥ ដែលជាផ្នែកនៃច្រករបៀងសេដ្ឋកិច្ចខាងត្បូង តាមរយៈជំនួយបច្ចេកទេសរួមទាំងការអភិវឌ្ឍសង្គមនិងអភិបាលកិច្ចល្អ និងតាមរយៈគម្រោងជំនួយឥតគិតថ្លៃខ្នាតតូចរបស់អង្គការក្រៅរដ្ឋាភិបាល។ ប្រទេសជប៉ុនមានបំណងបន្តផ្តល់ជំនួយរបស់ខ្លួន សម្រាប់ការអភិវឌ្ឍរបស់ប្រទេសនិងប្រជាជនកម្ពុជាដោយរួមបញ្ចូលទាំងកម្លាំងរបស់វិស័យឯកជនផងដែរ។

ដោយផ្អែកទៅលើសមិទ្ធិផលវិជ្ជមាននាឆ្នាំ២០១៣កន្លងទៅនេះ ឆ្នាំនេះ យើងមានបំណងបន្តពង្រីកបំលាស់ប្តូរប្រជាជននៃប្រទេសទាំងពីរឱ្យមានលក្ខណៈទូលំទូលាយបន្ថែមទៀត។

នាយករដ្ឋមន្ត្រីជប៉ុន **អាបេ** បានប្រកាសអំពីគំពោងដើម្បីជំរុញបំលាស់ប្តូរយុវជនជប៉ុននិងកម្ពុជាក្នុងកម្មវិធីដែលមានឈ្មោះថា "**JENESYS2.0**" ។ យុវជនជាង៣០០០នាក់នឹងត្រូវអញ្ជើញឱ្យចូលរួមក្នុងកម្មវិធីនេះក្នុងរយៈពេល៥ឆ្នាំខាងមុខ។ ខ្ញុំនឹងខិតខំប្រឹងប្រែងជម្រុញនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ ក្រោមកិច្ចសហប្រតិបត្តិការពីសំណាក់អតីតនិស្សិតកម្ពុជាដែលទទួលបានអាហារូបករណ៍ជប៉ុន ដែលមានចំនួនជាង៨០០នាក់ ក៏ដូចជាយុវជនដែលចូលរួមក្នុងកម្មវិធីយុវជននាវាអាស៊ីអាគ្នេយ៍ និងកម្មវិធីបំលាស់ប្តូរផ្សេងៗទៀត។ ខ្ញុំពិតជាមានសេចក្តីជឿជាក់យ៉ាងមុតមាំចំពោះការចូលរួមគាំទ្រពីសំណាក់ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍ទាំងនេះ។

ជាចុងក្រោយនេះ ទូលបង្គំជាខ្ញុំសូមអនុញ្ញាតថ្វាយនិងជូននូវសព្ទសាធុការពរមហាប្រសើរសូម សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ប្រកបដោយ សុខភាពល្អបរិបូរណ៍ និង សុភមង្គលយ៉ាងពេញលេញ នាឱកាសឆ្នាំថ្មី ឆ្នាំ២០១៤ នេះ។

**ពីខ្ញុំ គូម៉ាម៉ារ៉ូ យូជិ**

**ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**